នៃអ្នកបោះឆ្នោត

# កម្រងសិទ្ធិ

## អ្នកមានសិទ្ធិនៅខាងក្រោម ៖

1 **សិទ្ធិដើម្បីបោះឆ្នោត បើសិនអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះ។** អ្នកមានសិទ្ធិបោះឆ្នោត ប្រសិនអ្នក៖

- ជាពលរដ្ឋអាមេរិក កំពុងរស់នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា
- មានអាយុយ៉ាងតិចបំផុត 18 ឆ្នាំ
- បានចុះឈ្មោះនៅកន្លែងដែលអ្នករស់នៅបច្ចុប្បន្ន
- បច្ចុប្បន្នមិនបម្រើរដ្ឋឬជាប់ពន្ធនាគារសហព័ន្ធសម្រាប់ការកាត់ទោសពីបទឧក្រិដ្ឋមួយ,និង
- នៅពេលបច្ចុប្បន្ននោះ មិនបានរកឃើញដោយតុលាការថាអសមត្ថភាពផ្លូវចិត្ត ដើម្បីបោះឆ្នោតឡើយ

2 **សិទ្ធិដើម្បីបោះឆ្នោត បើអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះ សូម្បីតែឈ្មោះរបស់អ្នកមិននៅក្នុងបញ្ជីក៏ដោយ។** អ្នកនឹងបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្ដោះអាសន្ន ។ ការបោះឆ្នោតរបស់អ្នកនឹងត្រូវបានរាប់ ប្រសិនបើមន្ត្រីរៀបចំការបោះឆ្នោតកំណត់ថាអ្នកមានសិទ្ធិបោះឆ្នោត ។

3 **សិទ្ធិដើម្បីបោះឆ្នោត បើអ្នកនៅតែឈរក្នុងជួរនៅពេលកន្លែងបោះឆ្នោតបិទ។**

4 **សិទ្ធិដើម្បីបោះសន្លឹកឆ្នោតសំងាត់** ដោយគ្មានអ្នកណាម្នាក់រំខានដល់អ្នក ឬប្រាប់អ្នកពីរបៀបបោះឆ្នោត។

5 **សិទ្ធិដើម្បីទទួលសន្លឹកឆ្នោតថ្មី បើអ្នកបានធ្វើដោយភាន់ច្រឡំ** បើអ្នកមិនទាន់បានបោះសន្លឹកឆ្នោតរបស់អ្នកនៅឡើយ។ អ្នកអាច ៖

**ស្នើសុំមន្ត្រីបោះឆ្នោតនៅកន្លែងបោះឆ្នោតត** នូវសន្លឹកឆ្នោតថ្មី,

**ដូរសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្ររបស់អ្នក សំរាប់សន្លឹកឆ្នោតថ្មី** នៅឯការិយាល័យបោះឆ្នោត ឬនៅឯកន្លែងបោះឆ្នោតរបស់អ្នក, ឬ

**បោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្ដោះអាសន្ន។**

6 **សិទ្ធិដើម្បីទទួលជំនួយ ក្នុងការបោះសន្លឹកឆ្នោតរបស់អ្នក** ពីជនណាម្នាក់ដែលអ្នកជ្រើសរើស លើកលែងតែពីនិយោជក ឬអ្នកតំណាងសហជីពរបស់អ្នក។

7 **សិទ្ធិដើម្បីប្រគល់សន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ របស់អ្នក ដែលបានបំពេញនៅកន្លែងបោះឆ្នោតណាមួយ**ក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។

8 **សិទ្ធិដើម្បីទទួលសំភារៈការបោះឆ្នោត ជាភាសាមួយក្រៅពីអង់គ្លេស** បើមានប្រជាជនគ្រប់គ្រាន់នៅក្នុងតំបន់បោះឆ្នោតរបស់អ្នក និយាយភាសានោះ។

9 **សិទ្ធិដើម្បីសួរសំណួរទៅមន្ត្រីបោះឆ្នោត អំពីទំរង់ការបោះឆ្នោត** និងឃ្លាំមើលដំណើរការបោះឆ្នោត។ បើមនុស្សដែលអ្នកសួរ មិនអាចឆ្លើយសំណួររបស់អ្នកបានទេ គេត្រូវតែបញ្ជូនអ្នកទៅមនុស្សត្រឹមត្រូវដែលអាចឆ្លើយសំណួរបាន។ បើអ្នកមានឬកពារអុកឡុក គេអាចឈប់ឆ្លើយសំណួរអ្នក។

10 **សិទ្ធិដើម្បីរាយការណ៍សកម្មភាពខុសច្បាប់អ្វីមួយ ឬការបោះឆ្នោតដោយគែបន្លំ** ទៅមន្ត្រីបោះឆ្នោត ឬការិយាល័យរបស់រដ្ឋលេខាធិការ។

- គេហ៍ទំព័រ នៅ **www.sos.ca.gov**
- តាមទូរស័ព្ទ លេខ **(888) 345-4917**
- តាមអ៊ីមែល **elections@sos.ca.gov**

---

**បើអ្នកជឿថាអ្នកត្រូវបានបដិសេធនូវសិទ្ធិណាមួយទាំងនេះ** ទូរស័ព្ទទៅលេខពិសេសអ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការ តាមលេខឥតចេញថ្លៃជាសំងាត់ **(888) 345-4917**។